សាលាដំបូងខេត្តសៀមរាប

សាលក្រមព្រហ្មទណ្ឌ

លេខ ១៥ (គ)

ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០

-សំណុំរឿងព្រហ្មទណ្ឌលេខ ៦២៤

ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩

-សំណុំរឿងស៊ើបសួរលេខ ៥២១

ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩

-សំណុំរឿងជំនុំជម្រះលេខ ១២០៤

ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាអសាធារណៈនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ វេលាម៉ោង០៨ និង៣០នាទីព្រឹក នៅសាលសវនាការលេខ០១៦ ដោយមានសមាសភាព ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោកអនុប្រធាន [redacted] ជាប្រធានក្រុមប្រឹក្សា

លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជី សាលាដំបូង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦២៤ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ លើជនជាប់ចោទ ៖

១/- ឈ្មោះ [redacted] ដេត ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៣ មុខរបរបើកបរ ទីកន្លែងកំណើតនៅ[redacted] ខេត្តកំពង់ចាម ទីលំនៅមុនពេលចាប់ខ្លួនភូមិវិហារចិន សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ទី(វ) ម្តាយឈ្មោះ [redacted]ណា(វ) ប្រពន្ធឈ្មោះ[redacted]ធី មានកូនចំនួន ០១នាក់ ទោសពីមុន គ្មាន ។

- ឃុំខ្លួនតាមដីកាលេខ ៧៧១"ឃ.ខ"/១៩ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ។
- ដោយមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។
- ដោយមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។ (អវត្តមាន)
- ដោយមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

២/- ឈ្មោះ [redacted] ម៉ាញ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៨ មុខរបរគ្មាន កើតនៅខេត្តកណ្ដាល ទីលំនៅមុនពេលចាប់ខ្លួនភូមិ[illegible] សង្កាត់គោក

ចក ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] រី(រ) ម្តាយឈ្មោះ [redacted] ម៉ាលី(រ) នៅលីវ ទោសពីមុន គ្មាន ។

- ឃុំខ្លួនតាមដីកាលេខ ៧៧៥"ឃ.ខ"/១៩ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ។

៣/- ឈ្មោះ [redacted]អាត ហៅ រិទ្ធ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៥ មុខរបររត់ឡាន ទីកន្លែងកំណើត[redacted] ខេត្តសៀមរាប ទីលំនៅមុនពេលចាប់ខ្លួនភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted]ធី(រ) ម្តាយឈ្មោះ [redacted] សារឿន(រ) នៅលីវ ទោសពីមុន គ្មាន ។

- ឃុំខ្លួនតាមដីកាលេខ ៧៧៦"ឃ.ខ"/១៩ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ។

- ដោយមានលោកមេធាវី[redacted]និងលោក [redacted]ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤/- ឈ្មោះ [redacted]ប៊ុនធឿន ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៧ មុខរបរកូនជាងពិដាន ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តសៀមរាប ទីលំនៅមុនពេលចាប់ខ្លួនភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted]ពៅ(រ) ម្តាយឈ្មោះ [redacted] គីមលី(រ) នៅលីវ ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារមួយឆ្នាំ ពីបទល្មើសគ្រឿងញៀន ។

- ឃុំខ្លួនតាមដីកាលេខ ៧៧០"ឃ.ខ"/១៩ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ។

- ដោយមានលោក [redacted] (អត្តមាន) និងលោកស្រី[redacted]ជាមេធាវីការពារសិទ្ធិ ។

៥/- ឈ្មោះ [redacted] ផៃ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មិនចេះអក្សរ មុខរបរជាងសំណង់ ទីកន្លែងកំណើត[redacted] ខេត្តសៀមរាប ទីលំនៅមុនពេលចាប់ខ្លួនភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted]ធឿន(រ) ម្តាយឈ្មោះ [redacted] សុខហាន(ស) នៅលីវ ទោសពីមុន គ្មាន ។

- ឃុំខ្លួនតាមដីកាលេខ ៧៧២"ឃ.ខ"/១៩ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ។

៦/- ឈ្មោះ [redacted] គីមហុង ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៧ មុខរបរជាងពិដាន ទីកន្លែងកំណើត[redacted]ខេត្តសៀមរាប ទីលំនៅមុនពេលចាប់ខ្លួនភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ហៀម(ស) ម្តាយឈ្មោះ[redacted] សុខ(រ) នៅលីវ ទោសពីមុន គ្មាន ។

- ឃុំខ្លួនតាមដីកាលេខ ៧៧៣"ឃ.ខ"/១៩ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ។

៧/- ឈ្មោះ [redacted] ផាវ៉ា ហៅ ជីម ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៥ មុខរបរគ្មាន ទីកន្លែងកំណើតនៅ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលចាប់ខ្លួនភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ធី(ស) ម្តាយឈ្មោះ [redacted] សារឿន(ស) នៅលីវ ទោសពីមុន គ្មាន ។

- ឃុំខ្លួនតាមដីកាលេខ ៧៧៤"ឃ.ខ"/១៩ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ។

- ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤២ កថាខណ្ឌ១,២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿង ។

## អង្គហេតុកើតមានឡើងដូចតទៅ

កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ កម្លាំងការិយាល័យបទល្មើសគ្រឿងញៀន នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តសៀមរាប បានចុះបង្ក្រាបករណីចែកចាយគ្រឿងញៀននៅចំណុចភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ហើយបានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] អាត ដកហូតបានថ្នាំញៀនចំនួន០២កញ្ចប់ ទម្ងន់០,៨២ក្រាម និងឈ្មោះ [redacted] ដេត ដកហូតបានថ្នាំញៀនចំនួន០១កញ្ចប់ ទម្ងន់០,៣៣ក្រាម ហើយសមត្ថកិច្ចបានបន្តទៅឃាត់ខ្លួនឈ្មោះ [redacted] ផាវ៉ា ព្រមទាំងចាប់យកឧបករណ៍ប្រើប្រាស់ថ្នាំញៀនមួយចំនួន។ បន្ទាប់មកឈ្មោះ [redacted] អាត បានសហការជាមួយសមត្ថកិច្ចទៅចាប់មេក្លោងលក់ថ្នាំញៀនឈ្មោះ [redacted] ម៉ាញ ព្រមទាំងចាប់យកថ្នាំញៀនម៉ាទឹកកកចំនួន១៥កញ្ចប់ ទម្ងន់ ៥,២៥ក្រាម។ ក្រោយពីឃាត់ខ្លួនឈ្មោះ [redacted] ម៉ាញ ក៏មានឈ្មោះ [redacted] ប៊ុនធឿន, ឈ្មោះ [redacted] គឹមហុង និងឈ្មោះ [redacted] ផៃ បានទូរស័ព្ទមកទិញថ្នាំញៀនពីឈ្មោះ [redacted] ម៉ាញ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនអ្នកទាំងបីនាក់ និងធ្វើតេស្តទឹកនោមរកឃើញមានសារធាតុញៀន នៅក្នុងខ្លួនផងដែរ។

បានឃើញរបាយការណ៍សរុប ១០៤/២០១៩ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ របស់ការិយាល័យបទល្មើសគ្រឿងញៀន នៃកងរាជអាវុធហត្ថខេត្តសៀមរាប។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១០៦២ អ.យ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

បានឃើញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៦៦៤៦ /១៩ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] ដេត បានឆ្លើយថា: ខ្លួនសុំបដិសេធចម្លើយដែលខ្លួនបានឆ្លើយនៅនគរបាលយុត្តិធម៌ ត្រង់ចំណុចដែលខ្លួនបានឆ្លើយថា ថ្នាំញៀនក្នុងហោប៉ៅជារបស់ខ្លួន មិនមែនជារបស់ឈ្មោះ [redacted] អាត ទេ គឺ

ជារបស់ខ្លួនដែលបានទិញពីអ្នកផ្សេង រីឯចម្លើយដែលខ្លួនបានឆ្លើយនៅតំណាក់កាលរយៈការខ្លួនសុំបដិសេធទាំងស្រុង និងមិនទទួលស្គាល់ការចោទប្រកាន់មកលើខ្លួនឡើយ។ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ ឈ្មោះ [redacted] អាត បានមកយកខ្លួននៅផ្ទះ ហើយទៅផ្ទះរបស់គេ ពេលជិះបានពាក់កណ្ដាលផ្លូវ ក៏ត្រូវសមត្ថកិច្ចសង្ស័យហើយធ្វើការឃាត់ខ្លួន និងឆែកឆេររកឃើញថ្នាំញៀនចំនួន០១ កញ្ចប់ក្នុងហោប៉ៅខ្លួន។ ចំពោះថ្នាំញៀន គឺខ្លួនបានទិញក្នុងតម្លៃ ៥ ដុល្លារ ដើម្បីយកមកប្រើប្រាស់ម្នាក់ឯង។ កន្លងមកខ្លួនមិនធ្លាប់ជួញដូរគ្រឿងញៀននោះទេ គឺធ្លាប់តែប្រើប្រាស់បានចំនួន៤ទៅ៥ដងប៉ុណ្ណោះ។ សមត្ថកិច្ចបានដកហូតទូរស័ព្ទម៉ាក ហួវ៉ៃមួយគ្រឿង ក្រៅពីនេះមិនបានដកហូតអ្វីទេ។

- ជនជាប់ចោទឈ្មោះ [redacted] ម៉ាញ បានឆ្លើយថា: ខ្លួនទទួលស្គាល់ចម្លើយ ដែលខ្លួនបានឆ្លើយនៅតំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ ខ្លួនបានទៅយកថ្នាំញៀនពីឈ្មោះ [redacted] រិទ្ធ ចំនួន០១កញ្ចប់ ក្នុងតម្លៃ ២០០០០រៀល ទៅ ៣០០០០រៀល។ ខ្លួនស៊ីឈ្នួលយកថ្នាំញៀនឱ្យគេ ដោយមួយជើងគេឱ្យខ្លួនចាយ ២០០០០ រៀល ខ្លួនពុំដឹងថាអំពើនេះខុសច្បាប់ ព្រោះតែខ្លួនមានជីវភាពខ្វះខាត។ កន្លងមកខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនបានចំនួន ០២ដង ។

-ជនជាប់ចោទឈ្មោះ [redacted] អាត ហៅ រិទ្ធ បានឆ្លើយ: ខ្លួនទទួលស្គាល់ចម្លើយ ដែលខ្លួនបានឆ្លើយនៅតំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ ខ្លួនបានជួបជាមួយឈ្មោះ [redacted] សំណាង ដែលជាមិត្តរបស់ខ្លួន ពេលនោះគេបានផ្ញើរថ្នាំញៀនជាមួយខ្លួន ដោយប្រាប់ថាផ្ញើរមួយភ្លែត ស្រាប់តែមួយសន្ទុះក្រោយ ក៏មានសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។ ខ្លួនមិនធ្លាប់ជួញដូរថ្នាំញៀននោះទេ ធ្លាប់តែប្រើប្រាស់បានចំនួន១ ខែតែប៉ុណ្ណោះ ។

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន បានឆ្លើយថា: ខ្លួនទទួលស្គាល់ចម្លើយ ដែលខ្លួនបានឆ្លើយនៅតំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ ខ្លួនបានទាក់ទងទៅឈ្មោះ [redacted] ម៉ាញ ដើម្បីទិញថ្នាំញៀនយកមកជក់ចំនួន០១កញ្ចប់ ក្នុងតម្លៃ២០០០០រៀល ដោយខ្លួនយកមកជក់ម្នាក់ឯង តែពេលខ្លួនកំពុងធ្វើដំណើរទៅយក ស្រាប់តែសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។ កន្លងមកខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនចំនួន០៣ដង មកហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] ឆៃ បានឆ្លើយថា: ខ្លួនសុំបដិសេធចម្លើយដែលខ្លួនបានឆ្លើយនៅនគរបាលយុត្តិធម៌ ដោយសារនគរបាលបានបង្ខំឱ្យខ្លួនឆ្លើយ។ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ ខ្លួនបានជិះម៉ូតូជាមួយឈ្មោះ [redacted] និងឈ្មោះ [redacted] ប៊ុនធឿន ដើម្បីទៅរកម៉ូតូដែលពួកម៉ាកលួចទៅ ក្រោយមកពួកខ្លួនបានជិះត្រឡប់មកផ្ទះវិញតាមផ្លូវអង្គរ តែត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។ កន្លងមកខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនចំនួន០១ដង ជាមួយមិត្តភក្តិខ្លួនឈ្មោះ [redacted] ប៊ុនធឿន ។

-ជនជាប់ចោទឈ្មោះ [redacted] គីមហុង បានឆ្លើយថា: ខ្លួនទទួលស្គាល់ចម្លើយ ដែលខ្លួនបានឆ្លើយនៅតំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ ខ្លួនបានជិះម៉ូតូជាមួយឈ្មោះ [redacted] ប៊ុនធឿន និងឈ្មោះ [redacted] ឆៃ ដោយពួកខ្លួនបានជិះម៉ូតូតាមជាមួយគ្នា ក្នុងគោលបំណងទៅយកម៉ូតូពីមិត្តភក្តិរបស់ខ្លួន។ ពេលដែលជិះតាមផ្លូវក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។ កន្លងមកខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនចំនួន០៣ដង ជាមួយមិត្តភក្តិខ្លួនឈ្មោះ [redacted] ឆៃ ។

-ជនជាប់ចោទឈ្មោះ [redacted] ផាវ៉ា ហៅ ជីម បានឆ្លើយថា: ខ្លួនទទួលស្គាល់ចម្លើយ ដែលខ្លួនបានឆ្លើយនៅតំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ ពេលដែលខ្លួនកំពុងដេកនៅផ្ទះ ស្រាប់តែមានសមត្ថកិច្ចចូលទៅឃាត់ខ្លួនតែម្តង ហើយបានដកហូតយកឧបករណ៍សម្រាប់ប្រើប្រាស់ថ្នាំញៀន។ កន្លងមកខ្លួនមិនធ្លាប់ប្រើប្រាស់ជួញដូរគ្រឿងញៀននោះទេ គឺធ្លាប់តែប្រើប្រាស់ចំនួន០៥ដង ក្នុងរយៈពេល០១ខែកន្លះ។ សមត្ថកិច្ចបានដកហូតទូរស័ព្ទម៉ាក IPHONE6 ចំនួន១គ្រឿង ក្រៅពីនេះគ្មានដកហូតអ្វីទៀតទេ។

-តាមអំណានកំណត់ហេតុទទួលវត្ថុតាងលេខ ៣១៦/២០១៩ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ថា: បានទទួលបានទទួលវត្ថុតាងពីមន្ត្រីនគរបាលយុត្តិធម៌ ដូចខាងក្រោម ៖

១/. ស្រោមសំបុត្រពណ៌ស បិតជិត(គ្រឿងញៀន) មានស្នាមមេដៃរបស់ឈ្មោះ [redacted] ដេត និងមានហត្ថលេខារបស់លោក [redacted] ច័ន្ទតារា ចំនួន ០១ ។

២/. ស្រោមសំបុត្រពណ៌ស បិតជិត(គ្រឿងញៀន) មានស្នាមមេដៃរបស់ឈ្មោះ [redacted] ម៉ាញ និងមានហត្ថលេខារបស់លោក [redacted] ច័ន្ទតារា ចំនួន ០១ ។

៣/. ស្រោមសំបុត្រពណ៌ស បិតជិត(គ្រឿងញៀន) មានស្នាមមេដៃរបស់ឈ្មោះ [redacted] រាត និងមានហត្ថលេខារបស់លោក [redacted] ច័ន្ទតារា ចំនួន ០១ ។

៤/. ទូរសព្ទ័ម៉ាកHUAWEI Model:CUN-L22 គ្មានស៊ីម ពណ៌មាស ចំនួន ០១គ្រឿង ។

-ម៉ាក Iphone5 IMEI:01388500833437 មានស៊ីម Smart បែកកញ្ចក់មុខ ពណ៌ស ០១គ្រឿង ។

-ម៉ាក Nokia Model:220B មានស៊ីម Smart គ្មានសំបកក្រោយ ពណ៌ខៀវ ចំនួន០១ ។

-ម៉ាក Nokia ចុចពិល មានស៊ីម Smart ពណ៌ខ្មៅ ចំនួន០១ ។

៥/. សម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន ។

- តាមអំណានកំណត់ហេតុថ្លឹង និងដកហូតសំណាក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តសៀមរាប ថា: ម្សៅក្រាមពណ៌សថ្លាដែលបានដកហូតពីជនជាប់ចោទឈ្មោះ [redacted] រាត មានទម្ងន់ ០.៨១ក្រាម ទាំងសំបក ។

- តាមអំណានកំណត់ហេតុថ្លឹង និងដកហូតសំណាក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តសៀមរាប ថា: ម្សៅក្រាមពណ៌សថ្លាដែលបានដកហូតពីជនជាប់ចោទឈ្មោះ [redacted] ម៉ាញ មានទម្ងន់ ៤,៦៨ក្រាម ទាំងសំបក ។

-តាមអំណានកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា: បានចាប់យកវត្ថុតាង គឺម្សៅក្រាមពណ៌សចំនួន ០១កញ្ចប់ស្មើរនឹង ០,៣៣ក្រាម និងទូរស័ព្ទម៉ាកហ៊ូវៃ ពណ៌មាសចំនួន ០១គ្រឿង ពីឈ្មោះ [redacted] ដេត ។

-តាមអំណានកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា: បានចាប់យកវត្ថុតាង គឺម្សៅក្រាមពណ៌សថ្លាចំនួន ១៥កញ្ចប់ស្មើរនឹង ៥,២៥ក្រាម និងទូរស័ព្ទដៃម៉ាកណូគា ពណ៌ខ្មៅចំនួន ០១គ្រឿង ពីឈ្មោះ[redacted]ម៉ាញ ។

-តាមអំណានកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា: បានចាប់យកវត្ថុតាង គឺម្សៅក្រាមពណ៌សចំនួន ០១កញ្ចប់ស្មើរនឹង ០,៨២ក្រាម ទូរស័ព្ទដៃម៉ាក Iphone5 ពណ៌ក្រហម ចំនួន ០១គ្រឿង ពីឈ្មោះ[redacted]រាត ។

-តាមអំណានកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា: បានចាប់យកវត្ថុតាង គឺទូរស័ព្ទដៃម៉ាកណូគា ពណ៌ខៀវ ០១គ្រឿង ពីឈ្មោះ [redacted] រ៉េ ។

-តាមអំណានកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា: បានចាប់យកវត្ថុតាង គឺឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន និងថង់ផ្លាស្ទិចពណ៌ស កិបម៉ាត់បិទជិតសម្រាប់ច្រកថ្នាំញៀនមួយចំនួន ពីឈ្មោះ[redacted] ផារ៉ា ។

-តាមអំណានកំហេតុស្តីពីការទទួលស្គាល់សម្ភារៈ និងវត្ថុតាងចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា: ជនជាប់ចោទឈ្មោះ [redacted] ដេត បានទទួលស្គាល់ថា ម្សៅក្រាមពណ៌សចំនួន ០១កញ្ចប់ស្មើរនឹង ០,៣៣ក្រាម និងទូរស័ព្ទដៃម៉ាកហ៊្វាវ៉ៃ ពណ៌មាសចំនួន ០១គ្រឿង ជារបស់ខ្លួនពិតប្រាកដមែន។

-តាមអំណានកំហេតុស្តីពីការទទួលស្គាល់សម្ភារៈ និងវត្ថុតាង ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា: ជនជាប់ចោទឈ្មោះ[redacted] ម៉ាញ បានទទួលស្គាល់ថា ម្សៅក្រាមពណ៌សថ្លាចំនួន ១៥កញ្ចប់ស្មើរនឹង ៥,២៥ក្រាម និងទូរស័ព្ទដៃម៉ាកណូគា ពណ៌ខ្មៅចំនួន ០១គ្រឿង ជារបស់ខ្លួនពិតប្រាកដមែន ។

- តាមអំណានកំហេតុស្តីពីការទទួលស្គាល់សម្ភារៈ និងវត្ថុតាង ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា: ជនជាប់ចោទឈ្មោះ[redacted]រាត បានទទួលស្គាល់ថា ម្សៅក្រាមពណ៌សចំនួន ០១កញ្ចប់ស្មើរនឹង ០,៨២ក្រាម ទូរស័ព្ទដៃម៉ាកIphone5 ពណ៌ក្រហម ចំនួន ០១គ្រឿង ជារបស់ខ្លួនពិតប្រាកដមែន។

-តាមអំណានកំហេតុស្តីពីការទទួលស្គាល់សម្ភារៈ និងវត្ថុតាង ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា: ជនជាប់ចោទឈ្មោះ [redacted] រ៉េ បានទទួលស្គាល់ថា ទូរស័ព្ទដៃម៉ាកណូគា ពណ៌ខៀវ ០១គ្រឿង ជារបស់ខ្លួនពិតប្រាកដមែន។

- តាមអំណានកំហេតុស្តីពីការទទួលស្គាល់សម្ភារៈ និងវត្ថុតាង ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា: ជនជាប់ចោទឈ្មោះ[redacted]ផារ៉ា បានទទួលស្គាល់ថា ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន និងថង់ផ្លាស្ទិចពណ៌ស កិបម៉ាត់បិទជិតសម្រាប់ច្រកថ្នាំញៀនមួយចំនួន ជារបស់ខ្លួនពិតប្រាកដមែន។

-តាមអំណានកំណត់ហេតុវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា: បានម្សៅគ្រីមពណ៌ស១កញ្ចប់ ០,៣៣ក្រាម ដែលដកហូតពីឈ្មោះ [redacted] ដេត ដាក់ក្នុងស្រោមសំបុត្រ

ពណ៌សលេខ SM ០០១១២ ។

-តាមអំណាន់កំណត់ហេតុវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា: បានម្សៅគ្រីមពណ៌ស១១កញ្ចប់ ដែលដកហូតពីឈ្មោះ [redacted] ម៉ាញ ដាក់ក្នុងស្រោមសំបុត្រ ពណ៌សលេខ SM ០០១១១ ។

-តាមអំណាន់កំណត់ហេតុវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា: បានម្សៅគ្រីមពណ៌ស១កញ្ចប់ ដែលដកហូតពីឈ្មោះ [redacted] អាត ដាក់ក្នុងស្រោមសំបុត្រ ពណ៌សលេខ SM ០០១១៣ ។

-តាមអំណាន់កំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន១០៤/២០១៩ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ត្រីយុត្តិធម៌ថា: បានធ្វើតេស្តទឹកនោមរបស់ជនជាប់ចោទឈ្មោះ [redacted] ដេត, ឈ្មោះ [redacted] ម៉ាញ ,ឈ្មោះ [redacted] អាត, ឈ្មោះ [redacted] ប៊ុនធឿន, ឈ្មោះ [redacted] រ៉ៃ, ឈ្មោះ [redacted] គីមហុង និងឈ្មោះ [redacted] ធារ៉ា ជាលទ្ធផលវិជ្ជមាន(ជាតំរុយប្រភេទមេតំហ្វេតាមីន) ។

-តាមអំណាន់ដីកាបង្គាប់រក្សាទុកវត្ថុចាប់យកលេខ: ៤០០ ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាបថា: បង្គាប់តម្កល់វត្ថុតាងមាន៖

១/. ស្រោមសំបុត្រពណ៌ស បិតជិត(គ្រឿងញៀន) មានស្នាមមេដៃរបស់ឈ្មោះ [redacted] ម៉ាញ និងមានហត្ថលេខារបស់លោក [redacted] ច័ន្ទតារា ចំនួន ០១ ។

២/. ស្រោមសំបុត្រពណ៌ស បិតជិត(គ្រឿងញៀន) មានស្នាមមេដៃរបស់ឈ្មោះ [redacted] អាត និងមានហត្ថលេខារបស់លោក [redacted] ច័ន្ទតារា ចំនួន ០១ ។

៣/. ទូរសព្ទ័ម៉ាកHUAWEI Model:CUN-L22 គ្មានស៊ីម ពណ៌មាស ចំនួន ០១គ្រឿង ។

-ម៉ាក Iphone5 IMEI:01388500833437 មានស៊ីម Smart បែកកញ្ចក់មុខ ពណ៌ស ០១គ្រឿង ។

-ម៉ាក Nokia Model:220B មានស៊ីម Smart គ្មានសំបកក្រោយ ពណ៌ខៀវ ចំនួន០១ ។

-ម៉ាក Nokia ចុចពិល មានស៊ីម Smart ពណ៌ខ្មៅ ចំនួន០១ ។

៤/. សម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន ។

-តាមអំណានរបាយការណ៍សំយោគលេខ ១០៤/១៩ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ របស់ការិយាល័យប្រឆាំងបទល្មើសគ្រឿងញៀន នៃកងរាជអាវុធហត្ថ ខេត្តសៀមរាបបានសន្និដ្ឋាន: បទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងក្នុងមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ប្រព្រឹត្តឡើងដោយឈ្មោះ [redacted] អាត, ឈ្មោះ [redacted] ដេត និងឈ្មោះ [redacted] [illegible] មែន និងបទល្មើស ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងក្នុងមាត្រា៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ប្រព្រឹត្តឡើងដោយឈ្មោះ [redacted] ប៊ុនធឿន

ឈ្មោះ [redacted] ធារ៉ា, ឈ្មោះ [redacted] គីមហុង និងឈ្មោះ [redacted] រ៉ៃ ពិតប្រាកដមែន។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីធ្វើការពិភាក្សា សួរដេញដោលរួចមកឃើញថា យោងតាមរបាយការណ៍របស់ នគរបាលយុត្តិធម៌ ,កំណត់ហេតុធ្វើតេស្តរកសារធាតុញៀន មានភស្តុតាងដែលចោទប្រកាន់លើឈ្មោះ [redacted] រាត, ឈ្មោះ [redacted] ដេត និងឈ្មោះ [redacted]ម៉ាញ ពីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងឈ្មោះ [redacted] ប៊ុនធឿន, ឈ្មោះ [redacted] ធារ៉ា, ឈ្មោះ [redacted] គីមហុង និងឈ្មោះ [redacted] រ៉ៃ ពីបទ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ។ ដូច្នេះក្នុងនាមតំណាងអយ្យការ សុំតម្កល់ការចោទប្រកាន់ ដូចក្នុងដីកាសន្និដ្ឋានស្ថាពរ និងដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះដដែលនឹងប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់កំណត់។

## សេចក្តីសន្និដ្ឋានរបស់លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] ដេត និងជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន

ក្រោយពីបានពិភាក្សាដេញដោលរួចមកឃើញថាកូនក្តីរបស់ខ្លួនឈ្មោះ [redacted] ដេត បានបដិសេធការជួញដូរ ដោយមានភាពស៊ីសង្វាក់គ្នាជាមួយចម្លើយជនជាប់ចោទផ្សេងទៀត ហើយបានសារភាពថាបានចាត់ចែង ដូចនេះ ខ្លួនជាមេធាវីការពារសិទ្ធិ សុំឱ្យតុលាការប្តូរបទចោទដល់កូនក្តីរបស់ខ្លួន ។ ចំណែកឈ្មោះ [redacted] ប៊ុនធឿន បានសារភាពពីទោសកំហុសរបស់ហើយ ដូនេះខ្លួនជាមេធាវីការពារសិទ្ធិ សុំឱ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ។

## សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] ដេត

ក្រោយពីបានពិភាក្សាដេញដោលរួចមកក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] ដេត សុំធ្វើសេចក្តីសន្និដ្ឋានស្របនឹងសហភាតាមេធាវី [redacted] ។

## សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធារ៉ា និងជនជាប់ចោទឈ្មោះ [redacted] រាត

ក្រោយពីបានពិភាក្សាដេញដោលរួចមកឃើញថាឈ្មោះ [redacted] ធារ៉ា បានប្រើប្រាស់គ្រឿងញៀន មិនបានទិញទេ និងសមត្ថកិច្ចមិនមានដកហូតថ្នាំញៀនពីកូនក្តីខ្លួនទេ ដូនេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិជនជាប់ចោទ សុំឱ្យតុលាការប្តូរបទចោទពីចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មកប្រើប្រាស់ថ្នាំញៀនដោយខុស

ច្បាប់នូវសារធាតុញៀនវិញ ។ ចំណែកឈ្មោះ [redacted] រភត បានទិញថ្នាំញៀនដើម្បីប្រើប្រាស តែមិនទាន់បានប្រើប្រាស់នោះទេ ដូនេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិជនជាប់ចោទ សុំឱ្យតុលាការប្តូរបទចោទពីមាត្រា៤០ ទៅមាត្រា ៤២ វិញ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ដេត បានសំណូមពរ សុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] ម៉ាញ បានសំណូមពរ សុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] រភត បានសំណូមពរ សុំឱ្យតុហោការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន បានសំណូមពរ សុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] ឆៃ បានសំណូមពរ សុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] គីមហុង បានសំណូមពរ សុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] ធារ៉ា បានសំណូមពរ សុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន និងការប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ នៅចំណុចភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ពិតជាមានករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ដេត, ឈ្មោះ [redacted] ម៉ាញ,ឈ្មោះ [redacted] រភត និងករណី ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន, ឈ្មោះ [redacted] ឆៃ,ឈ្មោះ [redacted] គីមហុង, ឈ្មោះ [redacted] ធារ៉ា ប្រាកដមែន។

២-ចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ [redacted] ដេត ពុំមានភស្តុតាងដោះបន្ទុកគួរឱ្យជឿបានឡើយ។

៣-ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ាញ,ឈ្មោះ [redacted] រភត, ឈ្មោះ [redacted] ប៊ុនធឿន, ឈ្មោះ [redacted] ឆៃ,ឈ្មោះ [redacted] គីមហុង និងឈ្មោះ [redacted] ធារ៉ា មានភាពស៊ីសង្វាក់គ្នាពេលសវនាការ, ផ្ទៀងផ្ទាត់ស្ដីបស្ដូរ អយ្យការអមសាលាដំបូងខេត្តសៀមរាប, មន្ត្រីនគរបាលយុត្តិធម៌ រួមទាំងស៊ីសង្វាក់ផងដែរជាមួយកំណត់ហេតុ

ចាប់យកវត្ថុតាង, កំណត់ហេតុដកហូត, កំណត់ហេតុធ្វើតេស្តស្វែងយកសារធាតុ និងរបាយការណ៍សំយោគ ដែលអាចអោយជឿបានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ដូចដីកាបញ្ជូនមកជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ។

៤-ជនជាប់ចោទប្រាកដជាយល់ដឹងច្បាស់ថា ខ្លួនពុំត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពដូចការចោទប្រកាន់ខាងលើនេះទេ ប៉ុន្តែខ្លួននៅតែប្រព្រឹត្តដោយចេតនាទុច្ចរិត ដែលច្បាប់បញ្ញត្តិថាជាបទល្មើស និងផ្តន្ទាទោស ។

៥-អំពើរបស់ជនជាប់ចោទបានប៉ះពាល់ធ្ងន់ធ្ងរដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ។

៦-ជនជាប់ចោទមានកំរិតអាយុអាចទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ។

៧-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ ។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ៖

ក-ឈ្មោះ [redacted] ដេត , ឈ្មោះ [redacted] ម៉ាញ, ឈ្មោះ [redacted] រាត ហៅ រិទ្ធ, ឈ្មោះ [redacted] ប៊ុនធឿន ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ-ឈ្មោះ [redacted] ឆៃ, ឈ្មោះ [redacted] គីមហុង , ឈ្មោះ [redacted] ធារ៉ា ហៅ ជីម ពីបទ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ។

៩-វត្ថុចាប់យក ដែលតប្បីតុលាការសម្រេចរឹបអូស តាមមាត្រា៦២,មាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៩៣,មាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គឺ ៖

ក/. ស្រោមសំបុត្រពណ៌ស បិតជិត(គ្រឿងញៀន) មានស្នាមមេដៃរបស់ឈ្មោះ [redacted] ម៉ាញ និងមានហត្ថលេខារបស់លោក [redacted] ច័ន្ទតារា ចំនួន ០១ ។

ខ/. ស្រោមសំបុត្រពណ៌ស បិតជិត(គ្រឿងញៀន) មានស្នាមមេដៃរបស់ឈ្មោះ [redacted] រាត និងមានហត្ថលេខារបស់លោក [redacted] ច័ន្ទតារា ចំនួន ០១ ។

គ/. ទូរសព្ទ័ម៉ាកHUAWEI Model:CUN-L22 គ្មានស៊ីម ពណ៌មាស ចំនួន ០១គ្រឿង ។

-ម៉ាក Iphone5 IMEI:01388500833437 មានស៊ីម Smart បែកកញ្ចក់មុខ ពណ៌ស ចំនួន០១គ្រឿង ។

-ម៉ាក Nokia Model:220B មានស៊ីម Smart គ្មានសំបកក្រោយ ពណ៌ខៀវ ចំនួន០១គ្រឿង ។

-ម៉ាក Nokia ចុចពិល មានស៊ីម Smart ពណ៌ខ្មៅ ចំនួន០១ ។

ឃ/. សម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន ។

១០-សំដីចុងក្រោយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី គប្បីតុលាការពិចារណាលើការប្រព្រឹត្ត,អកប្បកិរិយា និងច្បាប់ជាធរមាន ។

## ហេតុដូច្នេះសម្រេច

១/-ផ្តន្ទាទោស ៖

ក/-ឈ្មោះ [redacted]ដេត ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០២ឆ្នាំ ០៦ខែ និងពិន័យជាប្រាក់ចំនួន ៤ ០០០ ០០០ (បួនលាន)រៀល ។

ខ/-ឈ្មោះ [redacted]ម៉ាញ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ ០៦ខែ និងពិន័យជាប្រាក់ចំនួន ៤ ០០០ ០០០ (បួនលាន)រៀល ។

គ/-ឈ្មោះ [redacted]អាត ហៅ រិទ្ធ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤ ០០០ ០០០ (បួនលាន)រៀល ។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២/-ផ្តន្ទាទោស ៖

ក/-/- ឈ្មោះ [redacted]ប៊ុនធឿន ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០២ឆ្នាំ ។

ខ/-ឈ្មោះ[redacted]ឆៃ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០២ឆ្នាំ ០៦ខែ និងពិន័យជាប្រាក់ចំនួន ៤ ០០០ ០០០ (បួនលាន)រៀល ។

គ/-ឈ្មោះ [redacted] គឹមហុង ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០២ឆ្នាំ ០៦ខែ និងពិន័យជាប្រាក់ចំនួន ៤ ០០០ ០០០ (បួនលាន)រៀល ។

ឃ/-ឈ្មោះ [redacted]ធារ៉ា ហៅ ជឹម ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០២ឆ្នាំ ០៦ខែ និងពិន័យជាប្រាក់ចំនួន ៤ ០០០ ០០០ (បួនលាន)រៀល ។

ពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ។

៣/.រឹបអូសវត្ថុចាប់យក តាមមាត្រា៦៣ ,៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៩៣ ,៩៤ នៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គឺ ៖ ស្រោមសំបុត្រពណ៌ស បិតជិត មានស្នាមមេដៃរបស់ឈ្មោះ [redacted] រភត និងមានហត្ថលេខារបស់អ្នកចូលរួម ចំនួន០១, ស្រោមសំបុត្រពណ៌ស បិតជិត មានស្នាមមេដៃរបស់ឈ្មោះ[redacted]ម៉ាញ និងមានហត្ថលេខារបស់អ្នកចូលរួម ចំនួន០១, ទូរស័ព្ទម៉ាក HUAWEI Model CUN-L22 មានស៊ីមស្នាត ពណ៌មាស ចំនួន០១គ្រឿង, ទូរស័ព្ទម៉ាក Iphone5 IMEI:013885008334137 មានស៊ីមស្នាត បែកកញ្ចក់មុខពណ៌ស ចំនួន០១គ្រឿង, ទូរស័ព្ទម៉ាក Nokia Model:220B មានស៊ីមស្នាត គ្មានសំបកក្រោយ ពណ៌ខៀវចំនួន០១គ្រឿង, ទូរស័ព្ទម៉ាក Nokia ចុចពិល មានស៊ីមស្នាត ចំនួន០១គ្រឿង និងសម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន។

សាលក្រមនេះជំនុំជម្រះអជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងប្រកាសជាអសាធារណៈនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

ហត្ថលេខា និង ត្រា ហត្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

[redacted]

---

“បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម”

ថ្ងៃអង្គារ ១២រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

សៀមរាប , ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩

បានឃើញ

ប្រធានក្រុមប្រឹក្សា

[redacted]

ក្រឡាបញ្ជីសវនាការ

[redacted]



Scanned with CamScanner